**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងាររវាង និយោជក និងនិយោជិត

ភាគី "ក" តំណាងនិយោជក និង ភាគី "ខ" តំណាងកម្មករនិយោជិត

ខ្ញុំបាទឈ្មោះ Jiradt Parichatkul តួនាទី ជានាយកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន **វីណា ហុងកុង ខំផែនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) មានអាសយដ្ឋាន៖ លេខ ៥៣ មហាវិថីមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ជាតំណាងនិយោជក ហៅថា ភាគី "ក"។

និង ខ្ញុំបាទឈ្មោះ **កែវ ឡា** តួនាទី ជាប្រធានការិយាល័យជួរមុខ និងជាប្រតិភូបុគ្គលិកនៃក្រុមហ៊ុន **វីណា ហុងកុង ខំផែនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) មានអាសយដ្ឋាន៖ លេខ ៥៣ មហាវិថីមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ជាតំណាងនិយោជិត ហៅថា ភាគី "ខ"។

កិច្ចសន្យាព្យួរការងារនេះ ធ្វើឡើងរវាង ភាគី "ក" តំណាងនិយោជក និង ភាគី "ខ" តំណាងកម្មករនិយោជិត ដោយភាគីទាំងពីរជាតំណាង បានព្រមព្រៀងគ្នាដោយដាក់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ១១ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤០៥នាក់ ដែលបំរើការងារនៅក្នុងក្រុមហ៊ុន **វីណា ហុងកុង ខំផែនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) សម្រាប់រយះពេល ០២ ខែ ដោយគិតចាប់ ពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២០ ក្នុងរយះពេលព្យួរកិច្ចសន្យាការងារនេះ ភាគី "ក" តំណាងនិយោជក នៃក្រុមហ៊ុន **វីណា ហុងកុង ខំផែនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) នឹងមិនផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតទាំង ១១ នាក់ រយះពេលពីរ(០២)ខែ គឺខែ សីហា និង កញ្ញា ឆ្នាំ ២០២០។

ក្រែងពុំប្រាកដយើងខ្ញុំទាំងពីរ ដែលជាតំណាងសូមចុះហត្ថលេខា និងផ្ដិតស្នាមមេដៃជាភស្តុតាង។

| ភាគី "ខ" តំណាងកម្មករនិយោជិត | ភាគី "ក" តំណាងនិយោជក |
| --- | --- |
| **កែវ ឡា** | Jiradt Parichatkul |